# ពូនភ្នំស្រូវនៅតំបន់ភ្នំបូក, អង្គរ

អាំង ជូលាន, គង់ វីរៈ, រស់ សុខុម

ខាងក្រោមនេ ះជាកំណត់ហេតុសង្ខេបនៃពិធីពូនភ្នំស្រូវ ដែលអ្នកស្រុកប្រារព្ធធ្វើនៅភូមិតានី, ឃុំរុនតាឯក, ស្រុកបន្ទាយស្រី, ខេត្តសៀមរាប កាលពីខែមករា ២០០៨។

ពូនភ្នំស្រូវជាពិធីដែលគេតែងធ្វើនៅពាសពេញប្រទេសកម្ពុជា ពេលដែលការងារស្រែចប់ស្រេចបាច់អស់គ្រប់គ្នា ដូច្នេះច្រើនតែធ្វើនៅខែបុស្ស។ បែបបទនោះតែងខុសគ្នាខ្លះៗ ពីតំបន់មួយទៅតំបន់មួយជាធម្មតា តែក្នុងពិធីដែលយើងខ្ញុំបានឃើញ ហើយនឹងយកមកបង្ហាញត្រួសៗនេះ មានកិច្ចចាស់បុរាណមួយដែលមិនយូរមិនឆាប់នឹងបាត់បង់ជាស្ថាពរ ពោលគឺកិច្ចហៅព្រលឹងស្រូវ។ នេះហើយមូលហេតុដែលនាំឲ្យកត់ត្រាទុក និងសង្ខេបជាពត៌មានដល់អ្នកអាន។

អ្នកស្រុកនៅតំបន់ដែលយកមកនិយាយនេះ ប្រកបការងារធ្វើស្រែជាសំខាន់បំផុត[១]។ ជាទូទៅ គេធ្វើស្រូវធ្ងន់និងស្រូវកណ្តាលដែលមានឈ្មោះផ្សេងៗ ភាគច្រើនជាខ្សាយ តែមានដំណើបខ្លះៗទុកធ្វើនំនែក ពេលមានបុណ្យទាន។ ស្រែ, ស្រូវ...ទាំងនេះជាវប្បធម៌របស់អ្នកស្រុក មានន័យថាជាប់ស្អិតនិងជីវិតរស់នៅរាល់ថ្ងៃនៅឡើយ ពុំដូចនៅប្រទេសអ្នកមាន ឬប្រទេសដែលកំពុងឡើងទៅជាអ្នកមាន ដែលដំណាំស្រូវឬធញ្ញជាតិដទៃទៀតគ្រាន់តែជាឧស្សាហកម្មដាំដុះ ដោយសារគ្រាន់តែជាមធ្យោបាយរកថវិកាប៉ុណ្ណោះ។ ដូច្នេះហើយបានជាគេទុកស្រូវស្មើរស្មើមនុស្ស ជាពិសេសគេប្រដូចទៅមនុស្សស្រី មានឈ្មោះថានាងនេះនាងនោះជាដើម មិនតែប៉ុណ្ណោះពេលក្លាយទៅជាបាយហើយ គេប្រៀបដូចម្តាយ ហៅថា "ព្រះមេ"។

[១] យើងខ្ញុំមិនលើកយកបាតុភូតថ្មីៗមកពោល គឺការលក់ដីធ្លីស្រែចម្ការ ដោយសារមានគម្រោង "អភិវឌ្ឍន៍"នោះទេ គឺនិយាយតែរឿងប្រពៃណី។

## ១. អ្នកធ្វើកិច្ចជញ្ជាត់

នៅម្តុំនេះមានភូមិមួយឈ្មោះ “ភូមិថ្នល់” ដែលពិសេសលើសគេត្រង់ថា អ្នកភូមិនេះចេះហៅព្រលឹងដោយមានធ្វើកិច្ចជញ្ជាត់ព្រលឹងជាដើម មិនថាហៅព្រលឹងមនុស្សឈឺ, ហៅព្រលឹងនាគដែលនឹងក្លាយជាសង្ឃ ឬហៅព្រលឹងស្រូវឡើយ។ យើងខ្ញុំធ្លាប់ឃើញក្រុមមនុស្សដដែលនេះទៅក្រុងសៀមរាប ដើម្បីហៅព្រលឹងអ្នកឈឺ, ទៅវត្តរុននៅជិតនោះដើម្បីហៅព្រលឹងនាគ, ទៅភូមិសក្តាដែលនៅឆ្ងាយពីនោះ តាមផ្លូវទៅប្រាសាទមាលា ដើម្បីហៅព្រលឹងស្រូវឲ្យគេ។ មេខ្យល់ដឹកនាំគេគឺយាយម្នាក់ឈ្មោះ “ទាវ” អាយុប្រមាណ៦៥ឆ្នាំ។ ប្តីគាត់ជាមនុស្សពិការ ហើយតែងជួយសូត្រពាក្យហៅព្រលឹងជាមួយអាចារ្យឯទៀត ឬព្រះសង្ឃជារឿយៗ[២]។ មានស្រីចំណាស់បន្តិច៣ ឬ៤នាក់ទៀត ដែលឯបយាយទាវ។ ក្រៅពីនោះ គឺយុវជនដែលច្រើនជាស្រីជំទង់ឬពេញក្រមុំប្រមាណ៦ឬ៧នាក់ ទៀត។ សូមបើកវង់ក្រចកបន្តិចនៅត្រង់នេះ ដើម្បីបញ្ជាក់ថាហៅព្រលឹងមនុស្សមានរបៀបធ្វើវែងឬខ្លី។ បើធ្វើខ្លី គឺត្រូវមានអ្នកសូត្រតាមក្បួន២ទៅ៣នាក់ ត្បិតអ្នកនោះច្រើនតែជាមនុស្សចាស់ ភ្នែកពុំសូវភ្លឺ ហើយត្រូវអានអក្សរក្រាំងនៅពេលយប់ ដូច្នេះត្រូវជួយគ្នា។ អ្នកសូត្រនោះជាញឹកញាប់មានត្រឹមតែជាអាចារ្យ តែជួនកាលអាចឃើញមានព្រះសង្ឃមួយអង្គដែរ។ ទោះជាខ្លីរបៀបនេះ ក៏ត្រូវមានមនុស្សម្នាច្រើន ហើយច្រើនតែជាមនុស្សស្រីសម្រាប់ស្រែកកំដរចេញជាឃ្លាផ្សេងៗជូនគ្នារដឹក ពេលណាអ្នកសូត្រពាក្យក្បួននោះចេញពាក្យថា “ព្រលឹង” ម្តងៗ។ កិច្ចនេះផ្តើមធ្វើនៅវាងម៉ោង៨យប់ ហើយចប់នៅប្រមាណមួយម៉ោងក្រោយមក[៣]។ នេះធ្វើខ្លី បើធ្វើវែង គឺនៅពេលមុនថ្ងៃរះ គេធ្វើកិច្ចជញ្ជាត់ព្រលឹងនៅក្រៅផ្ទះទៀត។ ជញ្ជាត់ព្រលឹងនេះហើយដែលជាកិច្ចការផ្តាច់មុខរបស់ក្រុម យាយទាវ។

សូមកុំច្រឡំថានេះជាអាជីព ត្បិតអ្នកទាំងនោះក្នុងមួយឆ្នាំមានឱកាសធ្វើឲ្យគេ (ហៅព្រលឹងមនុស្ស ឬហៅព្រលឹងស្រូវ) បីបួនដងប៉ុណ្ណោះ ពុំអាចយកកម្រៃបន្តិចបន្តួចដែលបានមកចិញ្ចឹមជីវិតឡើយ។ បើគិតថានេះជាឯកទេសទើបត្រូវជាង ព្រោះការងាររាល់ថ្ងៃគឺធ្វើស្រែ។ ថ្វីត្បិតតែពេលធ្វើកិច្ចឃើញស្លៀកពាក់ស្អាត។ តាមពិត គឺសុទ្ធសឹងជាអ្នកស្រែដែលមានជីវភាពមិនធូរធារប៉ុន្មានទេ។

---

[២] តែនៅទីនេះ ពុំរាប់បញ្ចូលតាជាប្តីនោះថាជាក្រុមយាយនោះឡើយ ត្បិតកិច្ចសូត្រយឺតៗធ្វើបទដោយមើលក្បួននោះទុកដាច់ដោយឡែក។ សូមអានតទៅទៀត។

[៣] យើងខ្ញុំនិយាយតែពីការសូត្រពាក្យហៅព្រលឹងសុទ្ធ មិនតភ្ជាប់និងកិច្ចអ្វីទៀតដូចជាការ “ដេកអង្កររាប” ជាដើមទេ។

## ២. ភូមិជំហារបុណ្យ

ភូមិដែលនាំអាទិ៍ធ្វើឆ្នាំនេះ គឺភូមិតានីដែលនៅប្រមាណ១ គ.ម. ខាងអាគ្នេយ៍ភូមិថ្នល់នោះ។ ធម្មតាបុណ្យរបៀបនេះតែងតែមានអ្នកផ្ដើមគំនិត តែយ៉ាងណាក៏បុណ្យនោះជាបុណ្យរួមរបស់សហគមន៍នីមួយៗដែរ ហើយគេពុំដែលនិយាយថាបុណ្យពូនភ្នំស្រូវរបស់តានេះ, យាយនោះ...ជាដើមទេ គឺគេថាបុណ្យពូនភ្នំស្រូវភូមិនេះ, ភូមិនោះ។ ក្នុងករណីដែលលើកយកមកបង្ហាញនេះ គឺតាម្នាក់ជាអ្នកផ្ដើមបុណ្យ តែរូបលេខ១ បង្ហាញឲ្យឃើញច្បាស់ថា សូម្បីតែកូនស្រីនិងចៅខ្លួនឯងបង្កើត, នៅផ្ទះជាប់គ្នាទៀងផង, ក៏យកស្រូវអង្ករនិងប្រាក់មកចូលដូចគេឯងឯទៀតទាំងអស់គ្នា រីឯតាក៏ឲ្យពរទៅវិញដូចឲ្យគេដទៃដែរ។ បានជាមានអ្នកផ្ដើមបុណ្យ មកពីត្រូវការប្រាក់កាសយកមករៀបចំឲ្យអធិកអធម តែអ្នកស្រុកភូមិខ្លួនផ្ទាល់ក្ដី អ្នកស្រុកជិតខាងក្ដី តែងតែមកចូលបុណ្យបណ្ដើរ។ ជាក្រោយ ដូច្នេះថវិកាដែលចាយនោះនឹងបានមកវិញខ្លះ។ ថ្វីត្បិតតែមិនដែលរួចខ្លួន[៤]។ បច្ច័យដែលគេយកមកចូលនោះច្រើន តែជាស្រូវ ដែលជួនកាលមានអង្ករខ្លះភ្ជាប់មកជាមួយនឹងប្រាក់កាសបន្តិចបន្តួចតាមលទ្ធភាពរៀងៗខ្លួន។ ជាស្វ័យប្រវត្តិស្រូវនិងអង្ករនោះទុកសម្រាប់វត្ថុទាំងស្រុងឥតដែលប៉ះពាល់ឡើយ។ អ្នកខ្លះចូលជានំនែកសម្រាប់ចែកគ្នាទទួលទាន ឬជាបន្លែបង្កាគ្រឿងគ្រៅសម្រាប់ធ្វើម្ហូប[៥]។ ប្រភេទចំណូលនេះមានផ្សេងៗទៀត តែប្រការមួយដែលសំខាន់បំផុតគឺការជ្រោមជ្រែងជួយគ្នា ជួយធ្វើអ្វីក៏ដោយឲ្យតែអាចជួយបាន ពុំចាំបាច់នរណាប្រើនរណាទេ ជា ពិសេសក្នុងការធ្វើម្ហូប ត្បិតអីការស្រស់ស្រូបអាហារ នោះមានបាយ



រូបលេខ១

[៤] យ៉ាងណាក៏អ្នកផ្ដើមបុណ្យចំណេញដែរ គឺចំណេញបានបុណ្យ។

[៥] ឧទាហរណ៍ ប្រុសៗខ្លះបបួលគ្នាបីបួននាក់ទៅដេកតាមព្រៃមួយយប់នៅភ្នំគូលែន ដើម្បីរកចុងសោម ឬចុងទន្សែជាដើម មកចូលបុណ្យធ្វើម្ហូប។

ល្ងាចនៅថ្ងៃទី១ផង (រូបលេខ១២) និងនំបញ្ចុកពេលព្រឹកថ្ងៃទី២ផង។ ណាមួយសម្រាប់ព្រះសង្ឃ គឺចាន់ពេលព្រឹកនៅរោងបុណ្យផង ហើយត្រូវរាប់បាត្រសម្រាប់ចាន់ត្រង់នៅវត្តទៀត។ រីឯប្រាក់កាសដែលគេចូលបន្តិចបន្តួចរៀងៗខ្លួននោះ គឺអ្នកផ្ដើមបុណ្យទុកសម្រាប់ឈ្នួលជាងមានអ្នកចាក់ចេកជាដើម, ឈ្នួលមេក្រូ, វីដេអូ, កម្រៃសម្រាប់ក្រុមអ្នកជញ្ជាត់ព្រលឹង, កម្រៃបន្តិចបន្តួចដល់អាចារ្យ។ល។ ប្រសិនបើសល់ គឺប្រគេនទៅវត្ត តែមិនដែលឮថាសល់ទេ គឺតែងតែខ្វះហើយអ្នកផ្ដើមបុណ្យចេញបង្គ្រប់។



រូបលេខ១២

៣. វត្ត

ពូនភ្នំស្រូវជាបុណ្យដែលជាប់នឹងរបរធ្វើស្រែ ពុំមែនជាបុណ្យសាសនាទេ តែបើឥតវត្ត, ឥតព្រះសង្ឃក៏ច្បាស់ជាដំណើរបុណ្យនោះផ្សេងស្រឡះពីការដែលបានឃើញ ត្បិតសាសនាជាប់ស្អិតរមួតនឹងសង្គមមិនអាចញែកដាច់ពី គ្នាឡើយ នេះបើនិយាយពីជនបទ។ របស់របរសំខាន់ៗដែលខ្ចីពីវត្តមកមានដូចជាទង់ច្រើនបែបយ៉ាង, ឆ័ត្រក្លោះ, ចានក្បានសន្ទឹកសន្ទាប់សម្រាប់អ្នកមកទាំងភូមិៗ, គ្រឿងបូជានៅលើគ្រែអាសន៍ និងព្រះបដជាដើម, គ្រឿងភ្លេងពិណពាទ្យមួយវង់ធំ...។ ម្យ៉ាងទៀត បើឥតវត្ត តើបានអាចារ្យមកពីណា, បានយុវជនណាមកលេងភ្លេងពិណពាទ្យ?។ល។ ពុំតែប៉ុណ្ណោះទេ ព្រះសង្ឃ ៩អង្គនិមន្តមកមួយចប់កម្មវិធីបុណ្យ។ រីឯវត្តក៏ទទួលផលដែរ គឺបានស្រូវអង្ករទាំងនោះយកទៅចាត់ចែងជាអម្រស់បានមួយភាគ។ នៅតានីក៏ដូចជានៅតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជាដែរ គេពុំដែលនិមន្តព្រះសង្ឃមកបុណ្យពូនភ្នំស្រូវឲ្យតែគ្រប់កិច្ច ដោយចម្រើនព្រះបរិត្តធម្មតាប៉ុណ្ណោះទេ។ នៅយប់ថ្ងៃទី១ ព្រះសង្ឃ៣អង្គមករួមបួងសួងនៅមុខស្រូវ ដែលប្រមូលផ្ដុំគ្នាពីការចូលបុណ្យ (រូបលេខ១៣) លុះស្អែកឡើងមុនចប់កម្មវិធី ក៏មានព្រះសង្ឃទេសន៍គ្រែពីរទៀត។



រូបលេខ១៣

## ៤. កិច្ចពិធី

បុណ្យនេះមានរយៈពេលពីរថ្ងៃ ឬបើពោលឲ្យច្បាស់ជាងនេះ គឺមួយរសៀលចូលដល់យប់ ហើយស្អែកឡើងមួយព្រឹកពេញ គឺថ្ងៃ៤រោចនិង៥រោចខែបុស្ស ត្រូវនឹងថ្ងៃ២៦, ២៧ ខែមករា ឆ្នាំ២០០៨។ នេះពុំនិយាយពីការរៀបចំជាច្រើនថ្ងៃមុននោះទេ ជាពិសេសរៀបចំប្រញាប់ដៃបំផុតមុនបុណ្យនោះមួយថ្ងៃ។ តាមពិត នៅក្នុងការរៀបចំគ្រប់បែបយ៉ាង គឺអ្នកស្រុកមករួមគ្នា ធ្វើតាមសមត្ថភាពនិងលទ្ធភាពរៀងៗខ្លួន។ នេះជាវិស័យសិក្សាសង្គមកិច្ចមួយយ៉ាងសំខាន់ ដែលយើងខ្ញុំពុំលាតត្រដាងនៅក្នុងកំណត់ហេតុនេះឡើយ គឺរៀបរាប់តែអំពីកិច្ចពិធីប៉ុណ្ណោះ។ រៀបរាប់នេះសោតក៏នឹងសង្ខេបត្រួសៗបំផុត កាលណានិយាយពីកិច្ចអ្វីៗដែលតែងមានជាធម្មតាក្នុងពិធីបុណ្យ ដូចជាប្រុងពលី, លើកទង់, ចម្រើនព្រះបរិត្ត, រាប់បាត្រ...ហើយបរិយាយក្បោះក្បាយជាងនេះតែអ្វីដែលពិសេស និងកិច្ចពិធីជាប្រធានបទនេះ។

អ្នកដែលធ្លាប់ឃើញបុណ្យផ្សេងៗនៅតាមភូមិតំបន់អង្គរដឹងហើយថា គេតែងរៀបចំកន្លែងបុណ្យនោះរបៀបណា។ មើលប្លង់ក្នុងរូបលេខ១៤នេះទៅ ឃើញថាទីតាំងផ្សេងៗនៃអ្វីៗដែលនៅក្នុងរាជវតិនោះ មិនខុសគ្នាអ្វីប៉ុន្មានពីការរៀបចំកន្លែងបុណ្យឯទៀតទេ។ នេះមកពីគំនិតទូទៅ គឺផ្លាឬលំហដែលកំណត់ដោយរាជវតិនេះជាសុខុមលោក, អ្វីដែលសំខាន់បំផុតក្នុងពិធីត្រូវនៅចំកណ្ដាល, រីឯទិសព្លៀសានតែងមានអ្វីដែលលើសទិសដទៃទៀត។

កន្លែងបុណ្យនោះជាទីស្រែ នៅជាប់មុខផ្ទះអ្នកផ្ដើមបុណ្យតែម្ដង ព្រោះដីពេលនេះទំនេរ ដោយសារនៅក្នុងខែបុស្សនៅឡើយ។ គេបោះបង្គោលឈើតូចៗរៀងគ្នាជារាជវតិដោយមានខ្សែទាក់ពីបង្គោលមួយទៅបង្គោលមួយ តែបើកចំហរជាទ្វារនៅកណ្ដាលទិសទាំងបួន។ ចំកណ្ដាលបរិវេណនោះ គឺរានសម្រាប់ហៅព្រលឹងស្រូវ ដែលគេធ្វើឡើងជា៣ថ្នាក់ (នៅរូបលេខ១៥ រានហៅព្រលឹងពុំទាន់តុបតែងលំអ ហើយគេពុំទាន់លើកយកមកដាក់ចំកណ្ដាលនៅឡើយ)។




រូបលេខ១៤



រូបលេខ១៥

រោងបុណ្យស្ថិតនៅប៉ែកខាងលិច ហើយចែកជាពីរផ្នែកដូចធម្មតា។ មួយផ្នែកក្រាលកន្ទេលផ្ទាល់លើដីជាផ្នែកទូលាយសម្រាប់មនុស្សម្នាទូទៅ ឯមួយផ្នែកទៀតនៅចុងខាងត្បូងជាផ្នែកសម្រាប់ព្រះសង្ឃ ហើយគេវាយក្តារជាថ្នាក់ឲ្យផុតពីដី។ នៅមុមនិរតី លើថ្នាក់នោះហើយដែលគេតម្កល់គ្រែអស្នាព្រះពុទ្ធរូប និងវណ្ណាប់នានាសម្រាប់បូជាព្រះ។ មានតែកន្លែងផុតពីដីនេះឯងដែលគេយកស្លឹកដូងមកបាំងធ្វើជាជញ្ជាំងខាងត្បូង និងខាងលិច។ បាំងនោះយកតែនាមទេ គឺធ្វើម្តេចឲ្យឃើញថាបើកចំហទៅរកទិសព្លៀសាន។ ទៅខាងចុងរោងម្ខាងទៀតវិញ គេបោះបង្គោលឈើតម្រៀបគ្នា មានឈើផ្តេកមកខ្វែងធ្វើជារបា ដោយយកកំណាត់កៅស៊ូក្រាលបាតព្រមទាំងពាត់ជុំវិញពីក្នុងនោះជាជញ្ជាំងសម្រាប់ដាក់ស្រូវ ដែលអ្នកស្រុកយកមកចូលបុណ្យ។ គេរៀបស្រូវដែលបានមកជាសុខុមលោកដែរ គឺកញ្ជើបន្តុបលើគ្នានៅកណ្តាលនោះជាភ្នំកណ្តាល ឯកញ្ជើ៤ទៀតនៅជុំវិញ ជាភ្នំបរិវារ (រូបលេខ១៦)។ ដូច្នេះឃើញថារៀបចំជង្រុកពិសេសនេះ ពុំខុសអ្វីពីការពូនភ្នំខ្សាច់នៅពេលចូលឆ្នាំ ឬក្នុងកិច្ចពិធីអ្វីមួយដែលមានន័យថា "ភដ្ត"[៦] ចាស់មួយចប់ហើយ ភដ្តថ្មីមួយទៀតចាប់ផ្តើមនោះឡើយ។ សូមសង្កេតថាមានខ្សែអំបោះដែលគេចងភ្ជាប់ភ្នំស្រូវទាំងនេះទៅគ្រែអស្នាព្រះសម្រាប់ព្រះសង្ឃសូត្រប្រស់ព្រំ។ ថ្វីត្បិតតែពេលនេះកំពុងពេញប្រាំង ហើយទាល់តែប្រមាណ៣ខែកន្លះទៀតទើបចាប់ធ្វើស្រែជាថ្មីក៏ដោយ គេធ្វើដូច្នេះមកពីន័យនៃបុណ្យនេះមានច្រើន ក្នុងនោះមានមួយដែលលេចចេញឡើងច្បាស់ គឺរៀបចំឲ្យការដុះដាលស្រូវនៅរដូវធ្វើស្រែបន្ទាប់មកមានប្រក្រតីភាព។ យើងនឹងឃើញន័យនេះកាន់តែច្បាស់នៅខាងមុខបន្តិចទៀត។ នៅជ្រុងព្លៀសាន ក្នុងបរិវេណរាជវតិ ក្រៅពីរានទិសតូចមួយដូចនៅមុមឯទៀតនោះមានរាន លើសគេពីរទៀត មួយគឺរាននិមរាជ ឯមួយធំជាងគេគឺរានពុទ្ធគុណ។ ដូចអាចជ្រាបស្រាប់ រានទាំងពីរនេះតែងតែនៅមុមព្លៀសានដូច្នេះឯង ត្បិតទាក់ទងនឹងភដ្តកប្ប ៖ ភដ្តចាស់មួយចប់ ភដ្តថ្មីមួយទៀតកើតឡើង[៧]។ រានទាំងប៉ុន្មាននេះ អាចារ្យយកអំបោះមកពាត់ឲ្យទាក់គ្នាហើយបន្តទៅភ្ជាប់នឹងរានហៅព្រលឹងស្រូវដែលនៅចំកណ្តាលបរិវេណ រួចទើបទៅភ្ជាប់នឹងគ្រែអស្នាទៀត។



រូបលេខ១៦

[៦] ពាក្យបាលីដើមគឺ "វដ្ត"។

[៧] សូមអាន អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប, ដំណើរជីវិតមនុស្សខ្មែរ មើលតាមពិធីឆ្លងវ័យ, ហនុមានទេសចរណ៍, ២០០៧, ទំព័រ៨៣_៨៤។

## ៤.១. ថ្ងៃទីមួយ

នៅថ្ងៃទីមួយ ប្រមាណពីម៉ោង៣រសៀលទៅ អ្នកស្រុកជិតខាងចាប់ផ្តើមយកស្រូវអង្ករ និងអ្វីផ្សេងៗដែលនិយាយពីលើមកហើយ មកចូលបុណ្យ ដោយប្រគល់ទៅឲ្យតាដែលជាអ្នកផ្តើមបុណ្យ។ ពេលតាទទួលព្រមទាំងជូនពរសព្វគ្រប់ហើយ ម្ចាស់ចំណូលនោះយកស្រូវទៅចាក់ក្នុងកន្លែងដែលទើបនឹងរៀបរាប់នេះដោយខ្លួនឯង ដោយមានអាចារ្យជួយសាទរនៅទីនោះ។ ទាល់តែប្រមាណម៉ោង៥កន្លះ ទើបយកមកចូលបានរួចរាល់គ្រប់គ្នា។ នៅត្រង់នេះ យើងខ្ញុំសូមបញ្ជាក់ថាក្រៅពីស្រូវយកមកប្រគេនវត្តនោះ គ្រប់គ្នាតែងតែមានស្រូវពូជម្នាក់មួយកញ្ចប់ ដែលគេយកទៅដាក់រាយគ្នានៅលើថ្នាក់ផ្សេងៗនៃរានហៅព្រលឹងស្រូវ (រូបលេខ៧)។ ប្រការនេះសំខាន់ខ្លាំងណាស់ ត្បិតបង្ហាញថាស្រូវដែល គេនឹងហៅព្រលឹងឲ្យនោះ គឺស្រូវពូជ។ បើប្រៀបទៅមនុស្ស ស្រូវនេះត្រូវតែរឹងមាំមានសុខភាពបរិបូណ៌ ព្រោះខ្លួននេះហើយដែលនឹងបង្កើតកូនចៅរីកសាយទៅទៀត។ មើលមកតែត្រឹមនេះក៏គង់យល់ហើយថា ភ្នំស្រូវពូនសម្រាប់វត្ត ជាភោគផលដែលបានមកហើយ រីឯពូជស្រូវដែលត្រូវហៅព្រលឹងឲ្យមុននឹងយកទៅបណ្តុះបណ្តាលក្នុងថ្នាលក្នុងស្រែតទៅទៀត គឺភោគផល ដែលសង្ឃឹមថានឹងបាននៅអនាគត។ ដូច្នេះកិច្ចដែលធ្វើចំពោះភ្នំស្រូវនៅមុខពំនូកភ្នំស្រូវក៏ត្រូវបែកឲ្យដាច់គ្នាពីកិច្ចដែលធ្វើលើរានហៅព្រលឹងស្រូវដែរ ថ្វីបើទាំងមូលនោះជាបុណ្យតែមួយ ហើយហៅទូទៅថា “បុណ្យពូនភ្នំស្រូវ” ដូច្នេះក៏ដោយ។



រូបលេខ៧

លុះឃើញថារានហៅព្រលឹងធ្វើរួចរាល់ហើយ មុននឹងឲ្យគេយកកញ្ចប់ស្រូវពូជមករៀបរាយគ្នាលើថ្នាក់ផ្សេងៗ អាចារ្យធំសូត្ររំងាប់ឈើដែលយកមកធ្វើរាន និងដើមចេកដែលយកមកចាក់លំអ ដោយនាំជាងទាំងប៉ុន្មាន ព្រមទាំងឧបករណ៍ប្រើប្រាស់ដូចជា រណារ, ពូថៅ, កាំបិត, ដែកចាក់...មករួមផង។

មុនបាក់រសៀលបន្តិច គេធ្វើកិច្ចលើកទង់រលកដោយផ្តើមពីខាងឦសានទៅ ហើយទើបលើកបន្តបន្ទាប់គ្នាទៀតតាមទិសប្រទក្សិណ។ កិច្ចដ៏អធិកអធមនេះ យើងខ្ញុំពុំយកមកបរិយាយទេ ដោយសារពុំពិសេសអ្វីតែនឹងបុណ្យពូនភ្នំស្រូវ[៨]។

[៨] សូមអាន អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប, *ដំណើរជីវិតមនុស្សខ្មែរ មើលតាមពិធីឆ្លងវ័យ*, ហនុមានទេសចរណ៍, ២០០៧, ទំព័រ៧៦។ មានការសង្ខេបន័យនៃទង់ដោយកញ្ញា ម៉ៅ សេងយាន និង អាំង ជូលាន នៅ www.khmerenaissance.info ជំពូកទី២, លេខរៀងទី២៥។

ក្រោយនេះបន្តិចមក ទើបគេប្រុងពលី នៅខាងត្បូងជាប់នឹងរោងបុណ្យជាធម្មតា ពោលគឺកិច្ចបូជាឱ្យក្រុងពាលី ដែលមានរឿងនិយាយថារស់នៅក្រោមប្រថពីយើងនេះ។ កិច្ចនេះក៏សំខាន់ តែយើងខ្ញុំពុំរៀបរាប់ដោយ ហេតុផលខាងលើនេះដែរ។

នៅក្បាលព្រលប់នេះហើយដែលព្រះសង្ឃ៩អង្គនិមន្តមកដល់។ ភាគច្រើននិមន្តមកពីវត្តរុន ដែលភូមិតានីជាចំណុះ។ គេនមស្ការព្រះរតនត្រៃរួច ព្រះសង្ឃចម្រើនព្រះបរិត្ត។ លុះចប់កិច្ចធម្មតានេះហើយ ឃើញថាយប់មកដល់ល្មម។ ពេលនោះអាចារ្យទាំងអស់នាំអ្នកស្រុកឱ្យបែរមករកភ្នំស្រូវនៅឯជើងវិញ ដើម្បីធ្វើកិច្ចបួងសួង។ ភ្នំស្រូវក្នុងយប់នោះ គេរៀបចំអុជទៀនមើលទៅឃើញស្អាតណាស់ សមនឹងកិច្ចបួងសួងដែលឱឡារិកខ្លាំងខ្លានោះដែរ។ សូមរំឭកថា កាលពីថ្ងៃ អាចារ្យបានយកអំបោះទៅចងភ្ជាប់រាននិមរាជនិងរានពុទ្ធគុណមកភ្នំស្រូវ ហើយបន្តទៅគ្រែអស្នាព្រះ មានន័យថាដែលបួងសួងនេះ គឺភ្ជាប់ភ្នំស្រូវទៅទេពដែលនៅទិសឦសាននោះផង ទៅព្រះត្រៃរត្ន័ដែលនៅប៉ែកខាងត្បូងនៃរោងបុណ្យផង។ ដូច្នោះហើយបានជាបួងសួងចប់ហើយ អាចារ្យនាំគេឯងបែរទៅព្រះសង្ឃវិញ ដើម្បីលោកប្រស់ព្រំឱ្យ។ ពុំតែប៉ុណ្ណោះទេ ពេលបួងសួងនោះ ព្រះសង្ឃ៣អង្គនិមន្តមកមុខភ្នំស្រូវនោះផ្ទាល់ ហើយបន់ស្រន់ដូចឧបាសកឯទៀតដែរ។ ជាមួយគ្នានឹងអាចារ្យសូត្រឧទ្ទិសនោះ គេមានបង្គោះគោម, ស្រែកចាកហ៊ោដោយមានភ្លេងពិណពាទ្យបន្លឺសម្លេងកងរំពង។ ពាក្យបួងសួងដែលអាចារ្យសូត្រឧទ្ទិសជាប់គ្នាប្រមាណជាង១០នាទីនេះ គឺអន្ទងហៅទេពនិករនានាទាំងក្នុងព្រាហ្មណ៍សាសនា ទាំងក្នុងព្រះពុទ្ធសាសនា មានពុទ្ធអង្គផ្សេងៗ ព្រមទាំងលោកបាល, នពគ្រោះ និងវិញ្ញាណក្ខ័ន្ធព្រះមហាក្សត្រដែលមានក្នុងរឿងនិទាននៃអ្នកស្រុក ដើម្បីយាងមកជាកសិណសាក្សីនៃពិធីពូនភ្នំស្រូវនេះ។ ក្នុងនោះទេពដែលសំខាន់ជាងគេ ច្បាស់ជាព្រះយមរាជហើយ បានជាគេបែរនៅទិសឦសាន ដែលមានរានយមរាជជាប្រធាន។

ប្រសិនបើបុណ្យនេះជាបុណ្យពូនភ្នំស្រូវធម្មតា ប្រហែលជាកម្មវិធីថ្ងៃទី១ចប់ត្រឹមនេះឯង។ ប៉ុន្តែនេះជាបុណ្យធំ ព្រោះមានគេហៅព្រលឹងស្រូវផង។ ដូចនិយាយពីមុនបន្តិចមកហើយ ន័យនៃកិច្ចនេះផ្សេងពីភ្នំស្រូវ គឺសំដៅទៅលើភោគផលនៅឆ្នាំខាងមុខ។ ដូច្នេះហើយបានជាគេហៅព្រលឹងឱ្យស្រូវពូជឱ្យបរិបូណ៌រឹងមាំ ដើម្បីបណ្តុះបណ្តាលកូនចៅជៅសណ្តានមួយជំនាន់ទៀត។

កិច្ចនេះចែកជាពីរផ្នែក។ ទីមួយ យប់នេះឯង ពេលបួងសួងឱ្យភ្នំស្រូវចប់សព្វគ្រប់ហើយ គេហៅព្រលឹងស្រូវពូជ គឺហៅនឹងមាត់។ ឯផ្នែកទី២ គឺស្អែកឡើងមុនភ្លឺ គេនឹងជញ្ជាត់ព្រលឹងដែលខ្ចាត់ព្រាត់ទៅនៅដោយដុប ដោយព្រៃបឹងបួរឯណា យកមកប្រគល់ឱ្យម្ចាស់ខ្លួនវិញ ពោលគឺស្រូវពូជ។ ក្រុមអ្នកហៅព្រលឹងស្លៀកពាក់ស្អាតបាតស្រស់គ្រប់គ្នាទាំង ក្មេងទាំងចាស់ មកជុំគ្នានៅមុខរាន (រូបលេខ១៨)។ យាយទាវចាត់ចែង សែនបាយសម្លដល់រាននោះមួយភ្លែតសិន រួចទើបប្រាប់ឱ្យអ្នកឯទៀតអង្គុយជុំវិញ លើថ្នាក់ក្រោមនឹងថ្នាក់បន្ទាប់នោះ។ អង្គុយលើថ្នាក់ណានោះ ឥតមានអ្វីកំណត់ទេ យាយទាវនឹងចាស់ៗឯទៀតក៏នៅថ្នាក់ក្រោមដែរ។ សំខាន់តែថ្នាក់លើបង្អស់ដែលសម្រាប់ឱ្យអ្នកសូត្រអានតាមក្បួន៣នាក់ ព្រមទាំង



រូបលេខ៨



រូបលេខ៩



រូបលេខ១០



រូបលេខ១១

ក្មេងស្រីអ្នកកាន់បាយព្រលឹងនៅជិតនោះ (រូបលេខ៩-១០)។ ប្រដាប់ប្រដារសម្រាប់ជញ្ជាត់ ក៏ទុកនៅលើនោះសិនដែរ ដូចជាឈ្នាង, កញ្ជើ, ឈើថ្លិច, វែកជាដើម។ មានតែចង្រ្កង់ទេ ដែលក្មេងប្រុសម្នាក់កាន់ ទុកសម្រាប់កន្ទ្រាក់រលាក់ឲ្យឮសូរ ពេលដែលគេនាំគ្នាបំពងសម្លេងម្តងៗ (រូបលេខ១១)។ ឯកូនចេក និងកូនអំពៅក៏ក្មេងព្រហ្មចារីត្រូវកាន់ដែរ។

ក្នុងចំណោមអ្នកអានពាក្យហៅ ព្រលឹង៣នាក់នោះ ២នាក់ជាអាចារ្យ ម្នាក់ទៀតជាក្មេងកម្លោះក្រុមយាយទាវដែរ ដែលមកហាត់ទម្លាប់ខ្លួន អានក្បួននឹងគេ។ គេសូត្រពាក្យហៅតាមក្រាំង ដោយបញ្ចេញជាបទយ៉ាងពិរោះ ហើយបើធ្វើសង្ខេបដោយសូត្រតែមួយចប់ គឺប្រព្រឹត្តទៅអស់ពេលប្រមាណជាងកន្លះម៉ោង។ សូត្រនេះចែកជាបីវគ្គ ហើយពេលដល់ចុងវគ្គនីមួយៗ បញ្ចប់ដោយពាក្យថា “អញ្ជើញនាងមកហើយ បំពេញផ្ទះយើង” ភ្លាមនោះ ក្រុមយាយទាវដែលនៅថ្នាក់ក្រោមបន្ទាប់ ក៏ស្រែកបង្អូកហៅឈ្មោះស្រូវនានា ចេញជាបទរាយគ្នារដឹក ដោយមានវាយគងផង អង្រួនចង្រ្កង់ផង កណ្តាលអាធ្រាតស្តាប់ពួគួរឲ្យស្ញើម[៩]។

ផ្នែកទីមួយនៃកិច្ចដែលទាក់ទងនឹងព្រលឹងស្រូវចប់ត្រឹមនេះ។ ថ្វីត្បិតតែភូមិថ្មល់នៅមិនឆ្ងាយប៉ុន្មានពីភូមិតានី ក្រុមហៅព្រលឹងនោះ មិនត្រឡប់ទៅផ្ទះវិញទេ ព្រោះស្អែកឡើងត្រូវតកិច្ចពីមុនពេលថ្ងៃរះទៀត។ រីអ្នកស្រុកខ្លះ  ជាពិសេសក្មេងៗនៅមើលកុនវីដេអូកន្លែងបុណ្យនោះទើសភ្លឺ។

[៩] ពាក្យហៅព្រលឹងស្រូវនេះ អាចមើលនៅក្នុង www.khmerenaissance.info, ក្នុងជំពូកលេខ១៦, លេខរៀងទី១៦។

## ៤.២.ថ្ងៃទីពីរ

ម៉ោងប្រមាណ៤កន្លះភ្លឺ ចាស់ៗដែលនៅសម្រាកក្នុងរោងបុណ្យនោះ ក្រោកនាំគ្នាទមស្ការថ្វាយបង្គំព្រះ តែទីនេះនិយាយតែពីកិច្ចពិធីប៉ុណ្ណោះ។ ក្រុមយាយទាវមកជុំគ្នាហើយសែនម្ហូបអាហារនៅរាននោះដូចកាលពីយប់មិញដែរ។ តែពេលនេះ សែនហើយមិនឡើងទៅលើរានភ្លាមទេ គឺនាំគ្នាទៅជញ្ជាត់ព្រលឹងស្រូវយកមកសិន។ គេឧបកិច្ចថាដើរទៅជញ្ជាត់តាមព្រៃ, តាមភ្នំ, តាមជ្រលង។ល។ តែតាមពិតគេដើរប្រទក្សិណរាជវតិនោះបីជុំ ដោយមានយាយទាវជាអ្នកនាំមុខ។ គាត់កាន់កូនឈ្នាងតូចមួយព្រមទាំងកាន់វែកមួយផង ដើម្បីបោយព្រលឹងដែលវង្វេងឲ្យមកវិញ។ ស្រីម្នាក់ទៀតដើរក្រោយជាប់នឹងគាត់, កាន់កូនកញ្ជើទុកសម្រាប់ដាក់ព្រលឹងដែលហៅបានមកវិញ ព្រមទាំងឈើថ្លេចមួយសម្រាប់នាំព្រលឹងនោះឲ្យមកតាមខ្លួន[១០]។ ផុតអំពីអ្នកទាំងពីរនេះមក ទើបមានអ្នកកាន់ផ្តិលខាត់, កាន់បាយព្រលឹង, កូនចេក, កូនអំពៅ... ដើរហែរៀងគ្នា។ ពេលដើរនោះ គេស្រែកបន្ទរហៅព្រលឹងដូចកាលពីយប់ដែរ *(រូបលេខ១២)*។

សូមបញ្ជាក់ថា នៅពេលក្រុមយាយទាវប្រទក្សិណជញ្ជាត់ព្រលឹង អាចារ្យទាំងពីរនាក់និងកម្លោះយប់មិញនោះនៅអង្គុយហៅព្រលឹងលើរានដូចកាលពីយប់ដូច្នេះដែរ។ លុះសន្មត់ថាជញ្ជាត់បានហើយ ក្រុមយាយទាវក៏ឡើងទៅលើរានវិញដូចកាលពីយប់ ហើយការសូត្រនោះក៏ដូចកាលពីយប់ដែរ។ កិច្ចនេះចប់ពេលព្រហាមស្រាងៗ ទើបគេឲ្យក្មេងប្រុសស្រីពីរនាក់ដែលកាន់កូនចេកនិងកូនអំពៅនោះ យកដើមទាំងពីរទៅដាំនៅក្បែរផ្ទះអ្នកផ្តើមបុណ្យ *(រូបលេខ១៣)*។



*រូបលេខ១២*



*រូបលេខ១៣*

[១០] ក្រៅពីហៅព្រលឹង គេតែងយកឈើថ្លេចប្រើក្នុងពិធីឆ្លងវ័យផ្សេងៗទៀត ដូចជាមង្គលការជាដើម ពេលដែលគេនាំកូនក្រមុំចេញពីបន្ទប់មកម្តងៗ គឺអ្នកនាំកាន់ឈើ នោះនៅចុងម្ខាង ឯកូនក្រមុំកាន់ចុងម្ខាងទៀតដើរតាម។

ព្រឹកព្រហាមនេះ អ្នកស្រុកចាប់ផ្ដើមប្រញាប់ដៃគ្រប់គ្នា ដោយត្រូវរៀបចំចង្ហាន់ប្រគេនលោកទាំង៩អង្គ ដែលទើបនឹងនិមន្តមកដល់រោងបុណ្យវិញ ជាពិសេសបន្ទាប់មកនោះរៀបចំអាហារសម្រាប់អ្នករួមបុណ្យទាំងមូលដែលមកច្រើនកុះករ។ រីឯកិច្ចពិធីវិញ ទាល់តែប្រមាណម៉ោង១០ព្រឹកទើបមានតទៅទៀត គឺអារាធនានិមន្តព្រះសង្ឃទេសនា។ ទេសន៍នោះ ហៅថា "អានិសង្សពូនភ្នំស្រូវ" មានគ្រែពីរ ឆ្លើយឆ្លងគ្នាក្នុងរយៈពេលប្រមាណកន្លះម៉ោង[១១]។

មិនយូរប៉ុន្មានផុតពីនោះមក គេនាំគ្នារាប់បាត្រព្រះសង្ឃដើម្បីយកចង្ហាន់ទៅវត្ត។ កិច្ចនេះអធិកអធមដែរ តែជាកិច្ចពុទ្ធសាសនាធម្មតា មិនថាបុណ្យអ្វីឬបុណ្យអ្វីឡើយ តែងឃើញមានញឹកញាប់ជាធម្មតា។ ដែលគួរឲ្យកត់សម្គាល់ គឺពេលកំពុងតែរាប់បាត្រនោះ អាចារ្យនាំអ្នកដែលបានដាក់បាត្ររួចហើយដើរប្រទក្សិណពាជុំរាជវតិនោះ ដោយមានទឹកមួយផ្តិលប្រស់ព្រំទៅខាងក្នុងបរិវេណផង។ ពេលនោះភ្លេងលេងរំពងអឺងកង មានមនុស្សស្រែកចាកហ៊ោទៀត។

ផុតអំពីនោះមក ទើបអាចារ្យនាំធ្វើកិច្ចចុងក្រោយបំផុតនៃពិធីបុណ្យ ហើយដែលពុំទាក់ទងអ្វីនឹងព្រលឹងស្រូវពូជទៀតទេ តែទាក់ទងនឹងភ្នំស្រូវដែលនឹងយកទៅវត្ត។ កិច្ចនេះ គឺបង្វិលពពិលជុំវិញភ្នំស្រូវ។ បើនិយាយតែពីកិច្ចពិធីសុទ្ធបុណ្យចប់នៅត្រឹមព្រឹកនេះវវាងម៉ោង១១។

សង្ខេបឲ្យខ្លីបំផុតមក បុណ្យហៅថា "ពូនភ្នំស្រូវ" នៅភូមិតានីនេះ មានកិច្ចធំបង្អស់ពីរពួក ឬពោលម្យ៉ាងទៀតថាមានន័យពីរ។ មួយជាសង្គមកិច្ច ដែលជាប់ទៅនឹងព្រះពុទ្ធសាសនា ពោលគឺភ្នំស្រូវដែលជាប្រភពអានិសង្សសម្រាប់ឧបាសកទាំងអម្បាលម៉ានផង ជាអម្រស់សម្រាប់ព្រះសង្ឃផង។ មួយទៀត តាមពិតទៅពុំពាក់ព័ន្ធអ្វីនឹងព្រះពុទ្ធសាសនាទាំងអស់ គឺជាកិច្ចដែលផ្អែកមូលដ្ឋានជីវចលសុទ្ធសាធ ពោលគឺហៅព្រលឹងស្រូវ ឲ្យស្រូវនេះមាំមួន ដើម្បីរីកសាយភោគផលនារដូវស្រែខាងមុខ។

---

[១១] ឃើញឈ្មោះប្រធានបទទេសន៍នោះ គេអាចនឹងច្រឡំថា ស្រង់ពីគម្ពីចាស់ណាមួយពិតប្រាកដនៃព្រះពុទ្ធសាសនា។ តាមពិត សាស្ត្រាសម្រាប់ទេសន៍ដែលមានឈ្មោះថា អានិសង្សទង់, អានិសង្សពិតាន, ... រហូតទៅដល់អានិសង្សបង្គន់ផង សុទ្ធសឹងជាសាស្ត្រាខ្លី។ សម្រាប់លោកទេសន៍តម្រូវទៅតាមបុណ្យនីមួយៗ។ បើគេប្រគេនទង់មកវត្ត លោកតែងទេសន៍អានិសង្សទង់ គឺថាអ្នកដែលធ្វើទង់ប្រគេនវត្តនោះ នឹងបានផលបុណ្យសោយសុខរហូតរាប់ម៉ឺន រាប់សែនឆ្នាំ។ ប្រគេនពិតានក៏ដូចគ្នា សង់បង្គន់សម្រាប់ព្រះសង្ឃនៅវត្ត ក៏ដូចគ្នាដែរ។ អានិសង្សនេះ គ្មានទាក់ទងអ្វីជ្រៅនឹងធម៌ព្រះពុទ្ធឡើយ គឺគ្រាន់តែជួយជម្រុញឲ្យមនុស្សម្នាផ្គត់ផ្គង់ឧបត្ថម្ភវត្តអារាមឲ្យបានទៀងទាត់ប្រសើរ។

អាំង ជូលាន, គង់ វីរៈ, រស់ សុខុម

## សង្ខេប

*ពូនភ្នំស្រូវនៅតំបន់ភ្នំបូក, អង្គរ*

ពិធីបុណ្យ “ពូនភ្នំស្រូវ” (ជួនកាលមានឈ្មោះផ្សេងពីនេះ) តែងមានធ្វើជាទូទៅនៅប្រទេសកម្ពុជា។ ទោះបីជារបៀបធ្វើខុសគ្នាខ្លះៗពីតំបន់មួយទៅតំបន់មួយក៏ដោយ ន័យទូទៅពុំខុសគ្នាឡើយ គឺថាជាពិធីកំណត់ពេលចប់ស្រែមួយរដូវ ហើយគេតែងតែធ្វើឡើងក្នុងបរិបទព្រះពុទ្ធសាសនា។

កំណត់ហេតុនេះបង្ហាញពិធីបុណ្យហៅថា ពូនភ្នំស្រូវដូច្នេះដែរ តែមានកិច្ចសំខាន់មួយផ្សេងបន្ថែមលើនោះទៀត ហៅថា “ហៅព្រលឹងស្រូវ” ដែលពាក់ព័ន្ធនឹងជំនឿជីវចលសុទ្ធសាធ។ ពិធីដែលបង្ហាញនេះ ជិតផុតរលត់ហើយ នៅសល់តែភូមិខ្លះៗនៅតំបន់ខាងជើងនៃប្រទេសកម្ពុជាប៉ុណ្ណោះដែលនៅធ្វើនៅឡើយ ដូចជានៅភូមិតានី, តំបន់អង្គរ, ដែលលើកយកមកនិយាយនេះ។ មួយវិញទៀត មនុស្សម្នាពុំស្គាល់របៀបធ្វើនិងន័យនៃកិច្ចហៅព្រលឹងស្រូវនោះជាទូទៅឡើយ។ ដូច្នេះហើយបានជាយកមកបង្ហាញដោយត្រួសៗ។

## Abstract

*Erection of "paddy mountains" in the Phnom Bok Region, Angkor*

The agrarian rite often called, as it is here, "erection of paddy mounts" is still regularly practiced throughout Cambodia. Ritual forms can vary slightly from one region to the next, but as a general rule these variations are of little consequence as they each are oriented toward the same goal. Marking the end of the annual cycle of rice cultivation, the ritual brings each household to make an offering of unhusked rice. Mixed together, the rice offerings are shaped into a mountain form or into five mountains arranged in a quincunx configuration, thus evoking cosmic or cyclical renewal and, finally, offered to the Buddhist monastery.

The present report concerns a less well-known but more complete version of this rite, performed in various locales of northern Cambodia. Based on observation of ritual performance in Tani village (Angkor region) in January 2008, the report presents an outline of the ritual process. The reason for publishing this report is quite straightforward: it appears that the long version of the ritual is nearing extinction. In contrast with that version of the ritual most commonly practiced today, the one documented here includes the exclusively animist component of "calling the souls" of the rice: not of the rice piled in the shape of a mountain and which will be eaten by the monks, but of the rice seed to be used for upcoming planting, for the upcoming cycle.

**Résumé**

*Erection des "monts de paddy" dans la région du Phnom Bok, Angkor*

Le rite agraire souvent appelé, comme ici, « Erection des monts de paddy » est encore communément pratiqué au Cambodge. Ses formes peuvent varier légèrement d'une région à l'autre, mais en règle générale les variations sont sans conséquence, car elles répondent au même but. Marquant, en effet, la fin du cycle annuel de la riziculture, il consiste en la participation de chaque maisonnée en don de riz non décortiqué. Tout le riz rassemblé est arrangé sous la forme d'un mont ou de cinq monts disposés en quinconce, évoquant ainsi le renouveau cosmique ou cyclique et, finalement, offert au monastère bouddhique.

Le présent rapport porte sur une version beaucoup moins connue, mais plus « complète », de ce rite, aujourd'hui encore observé ici ou là dans le nord du Cambodge. Fruit d'une observation au village de Tani (région d'Angkor) en janvier 2008, il respecte le déroulement schématique du rite, sans toutefois aller dans les détails. La motivation en est simple : tout porte à croire malheureusement que sous sa version longue, le rite est en voie d'extinction. A la différence de la version générale, celle-ci comporte en outre un deuxième élément rituel, exclusivement animiste, qui consiste à « appeler les âmes » du riz : pas de celui entassés en « monts » et qui va être consommé par les moines, mais des semences de riz pour la prochaine culture, pour le prochain cycle.